# សេចក្ដីថ្លែងការណ៍

## សម្ព័ន្ធប្រាក់ឈ្នួលអាស៊ីសូមទាមទារនូវការទទួលខុសត្រូវពីសំណាក់ក្រុមហ៊ុនម៉ាកយីហោ ស្របពេលដែលពន្ធសហរដ្ឋអាមេរិកអាចនឹងបង្កផលប៉ះពាល់ដល់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌកាត់ដេរជាច្រើនលាននាក់

*ខែកក្កដា ឆ្នាំ២០២៥*

សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី («អាហ្វា») គឺជាសម្ព័ន្ធសហជីពតំណាងឱ្យកម្មករកាត់ដេរនៅទូទាំងតំបន់អាស៊ី ក្រោកឈរប្រមូលគ្នាជំទាស់ទៅនឹងគោលនយោបាយពាណិជ្ជកម្មដែលបានគំរាមដល់ផលប្រយោជន៍របស់កម្មករនិយោជិត និងបង្កវិសមភាពជាសកលយ៉ាងធ្ងន់ធ្ងរ។ ការកំណត់ពន្ធនាពេលថ្មីៗនេះរបស់សហរដ្ឋអាម៉េរិកលើការនាំចូលផលិតផលសម្លៀកបំពាក់ពីអាស៊ីអាចនឹងបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរបស់កម្មករកាត់ដេរជាច្រើនលាននាក់ ដោយកម្មករនិយោជិតភាគច្រើនជាស្ត្រីបាននឹងកំពុងទទួលបានប្រាក់ឈ្នួលកម្រិតទាបរួចទៅហើយនោះ។

ការកំណត់ពន្ធបង្កហានិភ័យនាំឱ្យមានវិបត្តិមនុស្សធម៌ក្នុងទំហំស្រដៀងគ្នាទៅនឹងផលប៉ះពាល់នៃការរាតត្បាតនៃជំងឺកូវីដ ១៩ ដែរ នៅពេលដែលក្រុមហ៊ុនម៉ាកយីហោដើរចេញពីការទទួលខុសត្រូវរបស់ពួកគេ ដែលបង្កឱ្យមានការបញ្ឈប់កម្មករនិយោជិតពីការងារទ្រង់ទ្រាយធំ ការបិទរោងចក្រ ការកេងបន្លំប្រាក់ឈ្នួលដ៏រាលដាល និងការបង្កើនអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការយាយី។ ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ នឹងបង្កផលប៉ះពាល់ធ្ងន់ធ្ងរទៅលើកម្មករកាត់ដេរ ដោយភាគច្រើនជាស្ត្រី ដែលនឹងប្រឈមការអត់មានការងារធ្វើ និងធ្វើឱ្យមានភាពក្រីក្រកាន់តែខ្លាំងឡើង ខណៈក្រុមហ៊ុនម៉ាកយីហោផ្តល់អាទិភាពតែទៅលើប្រាក់ចំណេញជាជាងកម្មករនិយោជិត។

លោក វីរ៉ាន់តា ហ្គិនធីង អនុប្រធានសម្របសម្រួលនៃសម្ព័ន្ធប្រាក់ឈ្នួលអាស៊ីបានលើកឡើងថា «ពន្ធមិនអាចត្រូវបានប្រើប្រាស់ជាអាវុធក្នុងជម្លោះភូមិសាស្ត្រនយោបាយឡើយ។ ក្រុមហ៊ុនម៉ាកយីហោដែលទទួលបានផលចំណេញផលិតកម្មពីក្រុមហ៊ុនផ្គត់ផ្គង់មិនអាចនៅស្ងៀម ឬអសកម្មបានទេនៅពេលដែលពន្ធបង្កឱ្យមានផលប៉ះពាល់រហូតដល់ការបិទរោងចក្រ ឬការបញ្ឈប់កម្មករនិយោជិតពីការងារទ្រង់ទ្រាយធំជាដើម»។

ដើម្បីបង្កើតវិស័យកាត់ដេរសកលប្រកបដោយយុត្តិធម៌ និងសមធម៌ យើងស្នើឱ្យមានការពិចារណាទៅលើគោលការណ៍ស្នូលចំនួន ៤ យ៉ាង ដែលយកធ្វើជាមូលដ្ឋានគ្រឹះដើម្បីធ្វើឱ្យប្រសើរដល់ពាណិជ្ជកម្មសកលក្នុងវិស័យកាត់ដេរ ដូចខាងក្រោម៖

## ១.ជំទាស់ទៅនឹងការប្រើប្រាស់ពន្ធជាអាវុធ

ពន្ធគឺជាមធ្យោបាយសាមញ្ញមួយសម្រាប់រដ្ឋាភិបាលបង្កើនប្រាក់ចំណូល និងពង្រឹងសមត្ថភាពសេវាសាធារណៈ។ ប៉ុន្តែ ក្នុងបរិបទនៃសេដ្ឋកិច្ចផលិតកម្មសកល ពន្ធអាចមានទិសដៅពីរផ្សេងទៀត គឺ៖

ក. ការផ្លាស់ប្តូររចនាសម្ព័ន្ធផលិតកម្មឡើងវិញក្នុងទិសដៅសម្រេចឱ្យបាននូវភាពយុត្តិធម៌ត្រឹមត្រូវ និងបង្កើតកាលានុវត្តភាពការងារសម្រាប់កម្មករនិយោជិត និង

ខ. ការដាក់ចេញវិធានការទណ្ឌកម្មក្នុងបំណងទទួលផលចំណេញភូមិសាស្ត្រនយោបាយ ។

ក្នុងសេណារីយ៉ូទីមួយ ប្រសិនបើពន្ធពិតជាអាចប្តូរផលិតកម្មកាត់ដេរទៅកាន់សហរដ្ឋអាម៉េរិក និងផ្តល់ឱកាសការងារសម្រាប់កម្មករនិយោជិតនៅទីនោះ នេះជាសេណារីយ៉ូមួយដែលអាចផ្តល់ទឡ្ហីករណ៍បានថាការប្តូរផលិតកម្មនេះគឺដើម្បីផលប្រយោជន៍ការងារ។ ប៉ុន្តែទោះយ៉ាងណាក្តី បច្ចុប្បន្ននេះពុំមានសេណារីយ៉ូណាដែលបង្ហាញថាពិតជាមានការប្តូរផលិតកម្មសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាម៉េរិកនោះទេ។ តម្លៃផលិតកម្មនឹងឡើងខ្ពស់ខ្លាំងដែលនឹងលក់ក្នុងតម្លៃខ្ពស់ហួសពីលទ្ធភាពរបស់អ្នកប្រើប្រាស់នៅសហរដ្ឋអាម៉េរិក និងទីកន្លែងផ្សេងទៀតនៅលើពិភពលោក។ ពន្ធក្នុងវិស័យវាយនភណ្ឌនៅសហរដ្ឋអាម៉េរិកមិនអាចនាំទៅរកការស្តារផលិតកម្មកាត់ដេរត្រឡប់ទៅកាន់សហរដ្ឋអាម៉េរិកក្នុងទំហំច្រើនបានវិញនោះទេ។ ពន្ធនេះមានទិសដៅតែម្យ៉ាង គឺជាវិធានការទណ្ឌកម្មក្នុងគោលបំណងដណ្តើមឥទ្ធិពលភូមិសាស្ត្រនយោបាយ។

សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី សូមជំទាស់ទៅនឹងការកំណត់ពន្ធដែលមានលក្ខណៈជាការដាក់ទណ្ឌកម្មបែបនេះ ។ ពន្ធមិនអាចធ្វើជាអាវុធសម្រាប់ការដោះស្រាយជម្លោះភូមិសាស្ត្រនយោបាយបានឡើយ។

## ២. ការកែតម្រូវពន្ធត្រូវតែសមាមាត្រ និងស្មើភាព

ប្រសិនបើពន្ធត្រូវបានអនុវត្តមែននោះ ក៏ត្រូវតែអនុវត្តឱ្យបានសមាមាត្រ និងស្មើភាព។ អាហ្វា សូមជំទាស់នូវគោលនយោបាយពន្ធណាមួយដែលកែប្រែនូវតុល្យភាពពាណិជ្ជកម្មបច្ចុប្បន្នតាមមធ្យោបាយមិនយុត្តិធម៌ដែលផ្តល់ផលប្រយោជន៍ឱ្យប្រទេសមួយចំនួន ជាងប្រទេសផ្សេងៗទៀតក្នុងតំបន់។ ការកំណត់ពន្ធពុំមានតុល្យភាពនេះបង្កហានិភ័យធ្ងន់ធ្ងរដល់មូលដ្ឋានផលិតកម្មនៅអាស៊ី។ ជាការពិត ប្រព័ន្ធផលិតកម្មសកលផ្តល់នូវកាលានុវត្តភាពក្នុងការពង្រីកមូលដ្ឋានឧស្សាហកម្មការងារនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ទោះយ៉ាងនេះក្តី ការងារទាំងនោះទទួលបានការការពារតិចតួច និងប្រាក់ឈ្នួលទាបក្នុងខ្សែចង្វាក់ផលិតកម្ម ព្រមទាំងមានការគោរពសិទ្ធិការងារទាប ដែលនាំទៅរកការងារមានប្រាក់ឈ្នួលទាប។

ពន្ធដែលគ្រោងនឹងអនុវត្តនោះនឹងបង្កផលប៉ះពាល់ដល់ប្រព័ន្ធផលិតកម្មសកលដែលជាប្រភពនាំឱ្យមានកំណើនសេដ្ឋកិច្ចរយៈពេលយូរអង្វែង និងផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នា។ ការកំណត់ពន្ធត្រូវតែសមាមាត្រ និងមានតុល្យភាពជាមួយតម្លៃទំនិញ ដោយធានាថាបរិមាណផលិតផលដែលប្រទេសផ្សេងៗលក់ទៅកាន់សហរដ្ឋអាម៉េរិកនៅតែរក្សាបានទីផ្សារដដែល ឬពុំមានការប្រែប្រួលខ្លាំងឡើយ។ គោលនយោបាយពន្ធមិនត្រូវបានប្រើប្រាស់ដើម្បីបំបែកកម្លាំងពលកម្មក្នុងវិស័យវាយនភណ្ឌកាត់ដេរនៅតំបន់អាស៊ីឡើយ ឬក៏បង្កឱ្យមានការប្រកួតប្រជែងគ្នាដែលបង្កផលប៉ះពាល់ក្នុងវិស័យដូចគ្នានេះឡើយ។ កម្មករនិយោជិតចាំបាច់ត្រូវតែរួមសាមគ្គីគ្នាតស៊ូទាមទារឱ្យមានការគោរព និងការផ្តល់តម្លៃការងារនៅក្នុងតំបន់ និងរក្សាស្ថិរភាពពាណិជ្ជកម្ម។

### ៣. បង្វែរប្រាក់ចំណូលទទួលបានពីពន្ធទៅជាការគាំទ្រដល់កិច្ចការពារសង្គមដល់កម្មករនិយោជិត

កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌកាត់ដេរទទួលបានប្រាក់ឈ្នួលទាបជាងគេក្នុងចំណោមវិស័យឧស្សាហកម្មផ្សេងៗ ហើយអាស៊ីជាតំបន់ផលិតសម្លៀកបំពាក់ច្រើនជាងគេសម្រាប់ទីផ្សាពិភពលោក។ តំបន់អាស៊ីមានចំនួនប្រជាជនមានការងារធ្វើច្រើនជាងគេ ប៉ុន្តែប្រជាជននៅតែស្ថិតនៅក្នុងភាពក្រីក្រ។ ដោយទទួលបានប្រាក់ឈ្នួលទាបក្រោមបន្ទាត់នៃភាពក្រីក្រ កម្មការិនីរោងចក្រជួបការលំបាកក្នុងការចំណាយលើតម្រូវការមូលដ្ឋាន។

ពន្ធកំណត់ដោយរដ្ឋាភិបាលសហរដ្ឋអាម៉េរិកនឹងបង្កើនប្រាក់ចំណូលរបស់ពួកគេ។ ប៉ុន្តែពន្ធទាំងនេះក៏ជាទម្រង់មួយនៃការប្រមូលចំណូលពីប្រព័ន្ធផលិតកម្មសកល ហើយត្រូវទទួលស្គាល់ថាពន្ធនេះមានលក្ខណៈដូចគ្នាទៅនឹងការប្រមូលពន្ធលើផលិតផលអាជីវកម្មក្នុងប្រទេសដូច្នោះ។ ក្នុងគោលបំណងការពារយុត្តិធម៌ អាហ្វា សូមទាមទារឱ្យមានការចែករំលែកប្រាក់ចំណូលទទួលបានពីពន្ធដោយស្មើភាពតាមរយៈការប្រមូលពន្ធរបស់រដ្ឋាភិបាលសហរដ្ឋអាម៉េរិកលើខ្សែចង្វាក់ផ្គត់ផ្គង់សម្លៀកបំពាក់សកល។ ដោយ **យ៉ាងហោចណាស់ ៥០% នៃប្រាក់ចំណូលទទួលបានពីពន្ធ**ត្រូវតែចែករំលែកជាមួយប្រទេសផលិត ក្នុងទម្រង់នៃការផ្តល់ការគាំទ្រ**មូលនិធិសន្តិសុខសង្គម**សម្រាប់កម្មករកាត់ដេរ។ នេះនឹងចូលរួមចំណែកដល់ការកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរពីពន្ធដែលមានចរិតលក្ខណៈជាទណ្ឌកម្ម។ មូលនិធិនេះនឹងផ្តល់នូវការគាំទ្រសំខាន់ក្នុងករណីមានការប្រឈមនឹងការបញ្ឈប់កម្មករនិយោជិតពីការងារ ការបិទរោងចក្រ ឬការប្តូរផលិតកម្មទៅកាន់ប្រទេសផ្សេង ដោយបង្កឡើងដោយសារផលប៉ះពាល់ទាក់ទងនឹងពន្ធ។

ម្យ៉ាងទៀត វិធាននៃការរៀបចំពាណិជ្ជកម្មគួរតែបង្កើតជាកិច្ចព្រមព្រៀងទ្វេរភាគីជាផ្លូវការ ហើយរដ្ឋាភិបាលគួរតែបំពេញតួនាទីលើការបង្កើតមូលនិធិសន្តិសុខសង្គមនេះ។

## ៤. តម្រូវឱ្យក្រុមហ៊ុនម៉ាកយីហោទទួលខុសត្រូវក្នុងការផ្តល់សំណងជូនកម្មករនិយោជិត

នៅពេលដែលក្រុមហ៊ុនម៉ាកយីហោដកការបញ្ជាទិញពីរោងចក្រផ្គត់ផ្គង់ នោះនឹងមានផលវិបាកធ្ងន់ធ្ងរកើតឡើងភ្លាមលើកម្មករនិយោជិត។ កម្លាំងពលកម្មទាំងស្រុងត្រូវបានបញ្ឈប់ដោយពុំមានការជូនដំណឹង ហើយកម្មករនិយោជិតពុំមានប្រព័ន្ធឧបត្ថម្ភថវិកាឡើយ។ ការដកខ្លួនចេញរបស់ក្រុមហ៊ុនម៉ាកយីហោនេះ បន្តកើតឡើងដដែលៗក្នុងខ្សែចង្វាក់ផ្គត់ផ្គង់សម្លៀកបំពាក់សកល ជារឿងមួយដែលក្រុមហ៊ុនម៉ាកយីហោធ្វើឡើងដើម្បីការពារខ្លួនពួកគេពីហានិភ័យ ខណៈដែលផលវិបាកធ្លាក់មកលើកម្មករនិយោជិត។

យើងបានឃើញច្បាស់ហើយក្នុងអំឡុងពេលវិបត្តិកូវីដ១៩ ដោយក្រុមហ៊ុនម៉ាកយីហោជាច្រើនបានលុបចោលការបញ្ជាទិញទាំងយប់ និងបានបោះបង់ចោលរោងចក្រផ្គត់ផ្គង់នៅតាមបណ្តាប្រទេសផលិតសម្លៀកបំពាក់ជាច្រើន។ កម្មករនិយោជិតជាច្រើនលាននាក់ ដែលភាគច្រើនជាស្ត្រី ត្រូវបានបញ្ឈប់ពីការងារដោយពុំទទួលបានប្រាក់ឈ្នួល ប្រាក់បញ្ចប់កិច្ចសន្យាការងារ ឬការឧបត្ថម្ភណាមួយឡើយ។ ក្រុមហ៊ុនម៉ាកយីហោដែលចាកចេញបង្កឡើងដោយសារពន្ធនៅពេលនេះ អាចនឹងបង្កនូវផលប៉ះពាល់ដូចគ្នានឹងលើកមុនដែរ បើពុំបានដាក់ចេញវិធានការការពារជាបន្ទាន់ទេនោះ។

**ក្រុមហ៊ុនម៉ាកយីហោ មិនត្រូវដកខ្លួនចេញពីរោងចក្រ ដោយពុំទាន់បានចរចាជាមុនជាមួយក្រុមការងារចរចាជាមួយក្រុមហ៊ុនម៉ាកយីហោ (ABBG) តំបន់អាស៊ី** ដែលជាក្រុមការងារចរចាថ្នាក់តំបន់នៃសម្ព័ន្ធប្រាក់ឈ្នួលអាស៊ីឡើយ។ សេណារីយ៉ូ ដែលអាចកើតឡើងនៅត្រង់ចំណុចនេះ គឺ៖

១. នៅពេលមានការចាកចេញរបស់ក្រុមហ៊ុនម៉ាកយីហោដែលនាំឱ្យមានការបិទរោងចក្រទាំងស្រុង កម្មករនិយោជិតត្រូវតែទទួលបានសំណងពេញលេញក្នុងរយៈពេលនៃការបំពេញការងាររបស់ពួកគេ ហើយមិនត្រូវទុកឱ្យប្រឈមនឹងការអត់មានការងារធ្វើភ្លាមនោះឡើយ។ ការផ្តល់សំណងត្រូវតែទាន់ពេលវេលា តម្លាភាព និងអនុលោមតាមបទដ្ឋានជាតិ និងអន្តរជាតិ និងទទួលបានសំណងសមាមាត្រជាមួយនឹងកម្រិតនៃជំនួយរបស់ពួកគេ ជាមួយប្រទេសផ្គត់ផ្គង់ និងក្រុមហ៊ុន។

២. ក្នុងករណីមាន**ការបិទផ្នែកខ្លះ** ដែលនាំឱ្យមានការបញ្ឈប់ពីការងារ កាត់បន្ថយម៉ោង ឬការកាត់ប្រាក់ឈ្នួល កម្មករនិយោជិតត្រូវទទួលបានការការពារ។ កម្មករនិយោជិតដែលប្រឈមនឹងការផ្អាកការងារបណ្តោះអាសន្នដោយសារមានការកាត់បន្ថយការបញ្ជាទិញ ត្រូវទទួលបានសំណងក្នុងចំនួនយ៉ាងតិច ៧៥% នៃប្រាក់ឈ្នួលធ្វើការងារទៀតទាត់របស់ពួកគេក្នុងរយៈពេលបញ្ឈប់ពីការងារទាំងស្រុង។

ប្រសិនបើការបញ្ឈប់ការងារបណ្តោះអាសន្ននេះក្លាយជាអចិន្ត្រៃយ៍ ក៏ត្រូវផ្តល់សំណងពេញលេញផងដែរ។

នៅគ្រប់សេណារីយ៉ូ ការជួលកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ទាំងអស់ឱ្យចូលធ្វើការងារវិញគឺជាលក្ខខណ្ឌចាំបាច់ដែលត្រូវទទួលយកដោយពុំចាំបាច់មានការចរចានោះឡើយ។ ក្រុមហ៊ុនម៉ាកយីហោ ត្រូវទទួលខុសត្រូវដោយធានាថាផលប៉ះពាល់ដែលបង្កឡើងដោយការសម្រេចចិត្តក្នុងការផ្លាស់ប្តូរប្រភពផ្គត់ផ្គង់ដោយសារពន្ធនោះ ពុំធ្វើឱ្យប៉ះពាល់ដល់សហជីព ឬក៏សិទ្ធិរបស់កម្មករនិយោជិត។ ក្រុមហ៊ុនម៉ាកយីហោ ត្រូវតែគោរពសេចក្តីថ្លៃថ្នូ សិទ្ធិ និងតម្លៃរបស់កម្មករកាត់ដេរ។

ការងារត្រូវមានទស្សនវិស័យពាណិជ្ជកម្មដែលគាំទ្រដល់សេដ្ឋកិច្ចដែលមានតុល្យភាព ស្មើភាព និងនិរន្តរភាព ហើយនិងការអភិវឌ្ឍសង្គម និងបង្កើតសាមគ្គីភាពរួមគ្នាក្រោកឈរឡើងដ៏ស្វាហាប់ជំទាស់ទៅនឹងភាពអយុត្តិធម៌ពាណិជ្ជកម្មគ្រប់ទម្រង់។ តាមទស្សននេះ ចាំបាច់ត្រូវមានគោលការណ៍ពីរយ៉ាងគឺ៖

១. ត្រូវមានតុល្យភាពចំពោះការអភិវឌ្ឍមូលដ្ឋានឧស្សាហកម្មក្នុងចំណោមប្រទេសនានាទាំងអស់

២. ត្រូវមានការចែករំលែកប្រាក់ចំណូលដែលទទួលបានពីការប្រមូលពន្ធលើប្រព័ន្ធផលិតកម្មសកលប្រកបដោយនិរន្តរភាព និងសមភាព។

យើងខ្ញុំសូមជំទាស់នឹងប្រព័ន្ធពាណិជ្ជកម្មសកលនាពេលបច្ចុប្បន្ន ដែលក្រុមហ៊ុនម៉ាកយីហោធំៗបង្កើតប្រាក់ចំណូលរាប់លានដុល្លារ ខណៈកម្មករនិយោជិតដោយភាគច្រើនជាស្ត្រីកំពុងស្ថិតធ្លាក់នៅក្នុងភាពក្រីក្រ និងជំពាក់បំណុល។ ឥឡូវនេះដល់ពេលវេលាដែលត្រូវផ្លាស់ប្តូរវិធានពាណិជ្ជកម្មសកលថ្មីហើយ ដែលជាប្រព័ន្ធមួយដែលផ្តោតលើសុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់កម្មករនិយោជិត ពុំមែនត្រឹមតែក្នុងគោលដៅបង្កើតប្រាក់ចំណេញសម្រាប់បុគ្គលមានទ្រព្យសម្បត្តិស្តុកស្តម្ភមួយចំនួនតូចនោះឡើយ។ វិស័យវាយនភណ្ឌសកលត្រូវតែជាមូលដ្ឋានក្នុងកសាងយុត្តិធម៌ សមភាព និងទំនួលខុសត្រូវ។

ក្រុមហ៊ុនម៉ាកយីហោមិនត្រូវបានអនុញ្ញាតឱ្យបង្កើតប្រាក់ចំណេញតាមរយៈការងារដែលផ្តល់ប្រាក់ឈ្នួលទាបដល់កម្មករនិយោជិត ហើយនៅពេលមានវិបត្តិកើតឡើងក៏រត់គេចខ្លួនបត់នោះឡើយ។ រដ្ឋាភិបាលនានាមិនត្រូវប្រើពាណិជ្ជកម្មជាអាវុធដែលបង្កទុក្ខវេទនាដល់ជីវិតរស់នៅរបស់ប្រជាជនឡើយ។ យើងសូមអំពាវដល់សហជីព និងអង្គការដែលធ្វើការក្នុងវិស័យការងារនៅជុំវិញពិភពលោក មេត្តារួមសាមគ្គីជាមួយសហជីព និងអង្គការនានាក្នុងតំបន់អាស៊ី ពីព្រោះថាប្រសិនបើកម្មករនិយោជិតក្នុងប្រទេសណាមួយ ឬក្នុងវិស័យណាមួយទទួលរងការបំពានដោយអយុត្តិធម៌ នោះក៏ធ្វើឱ្យកម្មករនិយោជិតទាំងអស់ប្រឈមនឹងហានិភ័យផងដែរ។ តាមរយៈកាតព្វកិច្ចដែលក្រុមហ៊ុនម៉ាកយីហោត្រូវអនុវត្ត បដិភាគនៃប្រាក់ចំណូលពាណិជ្ជកម្មត្រូវតែផ្តល់ជូនទៅឱ្យដល់កម្មករនិយោជិត ហើយតាមរយៈការរួបរួមសាមគ្គីជំទាស់នឹងការអនុវត្តពាណិជ្ជកម្មដោយអយុត្តិធម៌ដែលកេងប្រវ័ញ្ចកម្មករនិយោជិត នោះយើងនឹងមានវិធានការជំទាស់៕